សាលារៀន គ្រូបង្រៀន (ពិសេសនៅតាមតំបន់ដាច់ស្រយាល) និងការបង្កើនមូលដ្ឋានសម្ភារៈថែមទៀត ដើម្បីដោះស្រាយកំណើនសិស្ស-និស្សិត ដែលកាន់តែកើនឡើងជាបន្តបន្ទាប់រាល់ឆ្នាំ

ពាក់ព័ន្ធ ជាពិសេសមាតា បិតា អ្នកអាណាព្យាបាលសិស្សក្នុងការបង្កើនបរិស្ថានរៀនសូត្រដល់សិស្សានុសិស្សឱ្យ

តទៅទំព័រ ១៥

ជំនន់ចាប់ស្រក។ ស្នើឱ្យអង្គភាពពាក់ព័ន្ធត្រូវពិនិត្យលទ្ធភាព និងត្រៀមលក្ខណៈផ្ដល់ពូជដំណាំផ្សេងៗទៀតជូនកសិករនៅមូលដ្ឋានណាដែលទទួលរងការ-

# មន្ត្រីរដ្ឋាភិបាលមូលដ្ឋាននៃប្រទេសសមាជិកអាស៊ាន៥ជួបជុំពិភាក្សានិងផ្លាស់ប្ដូរបទពិសោធន៍ល្អលើការងារអភិបាលកិច្ចមូលដ្ឋាននៅឥណ្ឌូណេស៊ី

**ទីក្រុងបាតាំ-ប្រទេសឥណ្ឌូណេស៊ី៖** សមាជគ្លងប្រទេសលើកទីបី នៃគម្រោងភាពជាដៃគូសម្រាប់អភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យនៅអាស៊ីអាគ្នេយ៍ (DELGOSEA) ដែលជាគម្រោងថ្នាក់តំបន់ជួយគាំទ្រដល់ការផ្លាស់ប្ដូរបទពិសោធន៍ល្អ ក្នុងការងារអភិបាលកិច្ចមូលដ្ឋាន បានប្រព្រឹត្តិទៅចំនួនពីរថ្ងៃ គឺនៅថ្ងៃទី ២៧ ដល់ ២៨ ខែកញ្ញា ឆ្នាំ២០១១ នៅសណ្ឋាគារ ណូវ៉ូតែល ទីក្រុងបាតាំ ប្រទេសឥណ្ឌូណេស៊ី ដែលក្នុងនោះរួមមានវគ្គសិក្ខាសាលាបណ្ដុះបណ្ដាលចំនួន១ថ្ងៃ ស្ដីពីការត្រួតពិនិត្យ និងវាយតម្លៃគម្រោង ។ គម្រោង DELGOSEA ត្រូវបានផ្ដល់សហមូលនិធិពីសហភាពអឺរ៉ុប (EU) និង មូលនិធិ-អាដិនណៅអែរ ស្ទីហ្វទុង (KAS) នៃប្រទេសអាល្លឺម៉ង់ តាមរយៈក្រសួងសហប្រតិបត្តិការនិងអភិវឌ្ឍន៍របស់ប្រទេសអាល្លឺម៉ង់ ។




*មន្ត្រីមូលដ្ឋានកម្ពុជាមកពីខេត្តកំពត បាត់ដំបង សម្ព័ន្ធភាពជាតិឃុំ-សង្កាត់ និងអង្គការខុនរ៉ាដ ចូលរួមកិច្ចប្រជុំ DELGOSEA ពីថ្ងៃ២៧ ដល់ថ្ងៃ៣០ ខែកញ្ញា ២០១១ នៅប្រទេសឥណ្ឌូណេស៊ី (រូបថត:សុផល)*

កិច្ចប្រជុំនេះមានអ្នកចូលរួមជាង ១០០នាក់ មកពីបណ្ដាក្រុងសាកល្បងចំនួន ១៦ ក្នុងប្រទេសដែលជាដៃគូទាំង ៥ ព្រមទាំងវត្តមាននៃតំណាងសមាគមរដ្ឋាភិបាលមូលដ្ឋាន មន្ត្រីរដ្ឋាភិបាលមូលដ្ឋានអង្គការសង្គមស៊ីវិល វិទ្យាស្ថានអប់រំនិងបណ្ដុះបណ្ដាលព័ត៌មាននានា។

ក្រៅពីវត្តមានសំខាន់ៗនៃអ្នកចូលរួមមកពីប្រទេសកម្ពុជាឥណ្ឌូណេស៊ី ហ្វីលីពីន ថៃ និងវៀតណាម កិច្ចប្រជុំនេះក៏មានការអញ្ជើញចូលរួមពីតំណាងសហភាពអឺរ៉ុប លោក អេរីក ហាប៊ែរ អ្នកផ្ដល់ប្រឹក្សាយោបល់ទីមួយ និងអ្នកស្រី ណូវី-

តទៅទំព័រ ៣៧

# ក្រសួងធនធានទឹកប្រាប់ឱ្យរៀបចំរក្សាទឹកទុកហើយ

**ភ្នំពេញ ៖** ស្ថានភាពជំនន់ទឹកភ្លៀង និងទឹកទន្លេមេគង្គបានធូរស្រាលមែនទែនហើយដោយនៅគ្រប់ស្ថានីយជលសាស្ត្រទឹកបានស្រកចុះទាំងអស់ ឯស្ថានភាពទឹកភ្លៀងវិញក៏កាន់តែខ្សោយដែរ ក្រសួងធនធានទឹកក៏បានជូនដំណឹងឱ្យចាប់ផ្ដើមរៀបចំរក្សាទឹកទុកសម្រាប់ការងារបង្កបង្កើនស្រូវប្រាំងនាពេលខាងមុខ ។

លោកម៉ៅ ហាក់ អគ្គនាយករងទទួលបន្ទុកកិច្ចការបច្ចេកទេស និងឡើងគោកនៅជ្រោយហាឡុងភាគខាងលើហាណូយនៅល្ងាចនេះ ទើបវាមានឥទ្ធិពលកាន់តែខ្លាំងធ្វើឱ្យនៅកម្ពុជាមានខ្យល់ខ្លាំង ហើយវាអាចនឹងធ្វើឱ្យមានភ្លៀងតិចតួចពេលរសៀលនៅថ្ងៃស្អែក(១តុលា)នោះ ។ ចំណែកឯព្យុះទី១៩ ឈ្មោះណាល់ហ្កែវិញពេលនេះវាមានសកម្មភាពនៅឆ្ងាយពីប្រទេសហ្វីលីពីននៅឡើយទេ ។ ព្យុះចំនួន១៩ និងវិសម្ពាធចំនួន៣បានកើតមានរួចហើយនៅក្នុងរដូវវស្សាឆ្នាំនេះ ។

មេគង្គពេលនេះនៅគ្រប់ស្ថានីយបានស្រកចុះលឿន រីឯស្ថានភាពទឹកភ្លៀងវិញនៅមាន តែវាមិនមានភ្លៀងច្រើនដូចពេលកន្លងមកនោះទេ ។ ដោយសារទឹកទន្លេមេគង្គស្រកលឿននេះហើយបានជានៅថ្ងៃទី៣០កញ្ញានេះក្រសួងធនធានទឹកបានចេញសេចក្ដីជូនដំណឹងមួយឱ្យមានការប្រុងប្រយ័ត្នក្នុងការរក្សាទឹកទុកសម្រាប់ការងារបង្កបង្កើនផលនៅពេលខាងមុខ ។

នៅថ្ងៃទី៣០កញ្ញាឆ្នាំ២០១១